ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ...០៨៤/២២...ក.ជ.ក

# របាយការណ៍ខែកុម្ភៈ
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅខែមីនា ឆ្នាំ២០២២

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ-១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ-១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ-១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ-១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួល ពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។
- គណៈកម្មាការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចុះអនុស្សរណៈនៃការយោគយល់គ្នា ចំនួន ០២ គឺ
  - ✓ ជាមួយអង្គការ **Erikshjalpen** ស្តីពីសកម្មភាពបង្ការ ទប់ស្កាត់ប្រយុទ្ធប្រឆាំងរាល់ទម្រង់នៃការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ (ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២)។
  - ✓ ជាមួយអង្គការ វីនរ៉ក់អន្តរជាតិ ដើម្បីរួមចំណែកលើកកម្ពស់ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងបង្កើនប្រសិទ្ធភាពវិធានការប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា (ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២)។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ១.១.១. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានសហការជាមួយ ក្រសួងអប់រំ យុវជន និងកីឡា អង្គការ Aple Cambodia និងសហការ ឧបត្ថម្ភដោយអង្គការ Plan International Cambodia អង្គការ UNICEF និងក្រុមហ៊ុន Smart Axiata រៀបចំយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បី

សុវត្ថិភាពអ៊ីនធឺណិត "រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារតាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ" ក្រោមអធិបតីភាពលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អ្នកចូលរួមប្រមាណ ៣៥០នាក់ នៅវិទ្យាស្ថានជាតិអប់រំ។

**ខ.១.២. ការអប់រំដោយផ្ទាល់**

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២២នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **៩.៦៩៦លើក** មានអ្នកចូលរួមសរុបចំនួន **៤២៦.១៨៤នាក់** (ធៀបនឹងខែមករា មានចំនួន **៣៧៦.១២២នាក់** គឺមានការកើនឡើងចំនួន ៥០.០៦២នាក់ ស្មើនឹង១១,៧៤ក្នុងនោះស្ត្រីចំនួន **២១៣.៨៣៥** នាក់។ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១១១ | ៨.៨៦៥ | ៤.៧២០ | | | |
| | សរុប ក្រសួង ស្ថាប័ន | ១១១ លើក | ៨.៨៦៥ នាក់ | ៤.៧២០ នាក់ | | | |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ៨០៨ | ៣១.៣០៧ | ១៧.៥០៣ | ៩៨២ | ៥៥.៧៨៨ | ២៩.៣៥៣ |
| ៣ | ខេត្តបាត់ដំបង | ៨០៧ | ៣៥.១៧៥ | ៨.៥៩៦ | ៤៩៤ | ១៤.៣៥០ | ៧.៦៤៧ |
| ៤ | ខេត្តពោធិ៍សាត់ | ៤៧៦ | ៤៦.០៩៧ | ២៧.៣៧៧ | ១២០ | ៣.៦៥៤ | ១.៨១០ |
| ៥ | ខេត្តសៀមរាប | ៧៧ | ៣.៦៤៧ | ២.១២៥ | | | |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.២២៨ | ៣៥.៨៦០ | ១៦.៣៩១ | ៥៨៧ | ១០.៩៦៣ | ៧.១៣២ |
| ៧ | ខេត្តកំពង់ចាម | ១.៩៦៥ | ១១២.២០៤ | ៥៨.១០៨ | ១.០៨១ | ៣១.៧១៤ | ១៦.៩៤២ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ១០ | ១.៨៥៤ | ១.២៨២ | | | |
| ១០ | ខេត្តស្វាយរៀង | | | | ២៧៧ | ៨.១៧៣ | ៤.៥៤៣ |
| ១១ | ខេត្តប៉ៃលិន | ១២០ | ២.៦៤១ | ១.០៣០ | ៧៥ | ៣.៣៥៣ | ១.២៩៧ |
| ១២ | ខេត្តកោះកុង | | | | ៣៣ | ៨០២ | ៣៩១ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | ១ | ១២០ | ៨០ | | | |
| ១៥ | ខេត្តតាកែវ | ២៨៧ | ៩.២៩២ | ៤.២៩១ | ៩៨ | ៣.២២២ | ១.៣៩៤ |
| ១៦ | ខេត្តក្រចេះ | ១៥ | ១.២៤០ | ៤៦៥ | | | |
| ១៧ | ខេត្តកែប | ១០ | ២.៨៥៨ | ៨៩១ | ១៦ | ១.០០៧ | ៣៤៣ |
| ១៨ | ខេត្តកំពង់ស្ពឺ | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | ១២ | ២៤០ | | | | |
| ២១ | ខេត្តព្រៃវែង | ១ | ៤០ | ២៥ | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ១ | ៨២ | | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | ៤ | ១.៦៣៦ | ៩៩ | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៥.៨២២ | ២៨៤.២៩៣ | ១៣៨.២៦៣ | ៣.៧៦៣ | ១៣៣.០២៦ | ៧០.៨៥២ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួន ៩.៦៩៦ លើក | | ចំនួនមនុស្សសរុប ៤២៦.១៨៤ នាក់ | | ចំនួនស្ត្រី ២១៣.៨៣៥ នាក់ | |

### ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិចត្រូនិក

- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមរយៈផេកហ្វេកប៊ុក មានអ្នកចូលមើលចំនួន ៨.៨៣០នាក់។
- ខេត្តសៀមរាបៈ មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM103MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ចំនួន ៦៤លើក (ផ្សាយផ្ទាល់ ២០លើក និងចាក់ផ្សាយឡើងវិញ ៤៤លើក)។
- ខេត្តតាកែវ បានផ្សព្វផ្សាយច្បាប់នានាពាក់ព័ន្ធ ស្ដីពីការចូលរួមទប់ស្កាត់ជំងឺកូវីដ-១៩ និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈវិទ្យុគោគធ្លក និងទូរទស្សន៍គោកធ្លកសរុបចំនួន ១.៨១៧អត្ថបទ/លើក និងផ្សព្វផ្សាយព័ត៌មានតាមស្ថានីយ៍វិទ្យុFM92.5MHz អំពីសកម្មភាពនានាពាក់ព័ន្ធ ស្ដីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដោយអំពើជួញដូរ និងការធ្វើជីវកម្មផ្លូវភេទ និងផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្រ្កាបអំពើជួញដូរមនុស្ស ការប្រើប្រាស់គ្រឿងញៀង និងឃ្លីប អប់រំផ្សេងៗសរុបចំនួន ២.០៩៧លើក/អត្ថបទ។

### ខ.១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ

- ខេត្តកំពង់ចាមៈ
  - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនចំនួន ០២លើក ស្ដីពីការពង្រឹងប្រសិទ្ធភាពផ្សព្វផ្សាយ និងទប់ស្កាត់ភាពមិនប្រក្រតី ក្នុងថ្ងៃទិវាបុណ្យនៃក្ដីស្រឡាញ់។
  - មន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត បានចូលរួមជាវាគ្មិនចំនួន ០៤លើក ស្ដីពីការអប់រំផ្សព្វផ្សាយចំណេះដឹងដល់ប្រជាពលរដ្ឋ ពីផលប៉ះពាល់នៃអំពើជួញដូរមនុស្ស ពង្រឹងប្រសិទ្ធភាពផ្សព្វផ្សាយ និងទប់ស្កាត់ការធ្វើចំណាកស្រុកដោយខុសច្បាប់ ការទប់ស្កាត់ភាពមិនប្រក្រតី ក្នុងថ្ងៃទិវាបុណ្យនៃក្ដីស្រលាញ់ និងការបណ្ដុះបណ្ដាលជំនាញដាំដុះដល់ស្ត្រី ដើម្បីលើកស្ទួយជីវភាពគ្រួសារ។

## ខ.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- ខេត្តបន្ទាយមានជ័យៈ អង្គការសាម៉ារីតាន់ភឺស ផ្ដល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាពចំនួន ២៦៧នាក់ (ស្ត្រី ១២២នាក់)។
- ខេត្តបាត់ដំបងៈ អង្គការសាម៉ារីតាន់ភឺស បានផ្ដល់ការអប់រំ និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ស្ដីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករចំនួន ៨២នាក់ (ស្ត្រី ៣០នាក់) កុមារ ០៥នាក់។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេសទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទងសរុបចំនួន ១៨៤.៩៨១នាក់ (ស្រី ៨១.៩៩៨នាក់) អនីតិជន ៣.០៥៧នាក់ (ស្រី ១.២៦៨នាក់)៖
  - ចេញទៅដោយស្របច្បាប់ ចំនួន ១៣៦.០០១នាក់ (ស្រី ៦០.១៩១នាក់) អនីតិជន ១.០៦០នាក់ (ស្រី ៤៥៤នាក់) និងមិនស្របច្បាប់ចំនួន ៤៨.៧៩៨នាក់ (ស្រី ២១.៧៤៣នាក់) អនីតិជន ១.៩៩៣នាក់ (ស្រី ៨១០នាក់)។
  - ដាច់ការទាក់ទងចំនួនន ១៨២នាក់ (ស្រី ៦៤នាក់) អនីតិជន ០៤នាក់(ស្រី)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តចំនួន០៣ បានធ្វើការបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ និងបានធ្វើកិច្ចសន្យាអប់រំ ណែនាំកុំឱ្យចំណាកស្រុកខុសច្បាប់ ទៅក្រៅប្រទេសទៀត។ ក្នុងនោះមាន៖
  - ខេត្តបន្ទាយមានជ័យចំនួន០៣លើក មនុស្សចំនួន ៦៨នាក់ (ស្រី ២៩នាក់) អនីតិជន ០៦នាក់។
  - ខេត្តបាត់ដំបង ចំនួន ០១លើក មនុស្សចំនួន ០៣នាក់ (ស្រី ០២នាក់។
  - ខេត្តឧត្តរមានជ័យ ចំនួន ០១លើក មនុស្សចំនួន ០៩នាក់ (ស្រី ០៤នាក់)។

### ខ.៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលក្រចេះ តាកែវ និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន ១៥៩គោលដៅ មនុស្សចំនួន ២៨៥នាក់ (ស្រី ២០៩នាក់)។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តព្រៃវែង ក្រចេះ រតនគិរី និងខេត្តបន្ទាយមានជ័យ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទ ចំនួន ០៨លើក។

### ខ.៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ១១៤គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ និងបានប្រមូលព័ត៌មានពីការសួរសុខទុក្ខនារីខ្មែរ ដែលរៀបការទៅរស់នៅប្រទេសកូរ៉េខាងត្បូងចំនួន ១១នាក់ (ស្រី ០៩នាក់)។

## ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- ខេត្តប៉ៃលិន៖ បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សេឡូ កាស៊ីណូ ឡឥដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំងពលកម្មកុមារទេ។

## គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

#### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ១៤ករណី( ធៀបនឹងខែមករា មានចំនួន ១៥ករណី ថយចុះចំនួន ០១ករណី) ស្មើនឹង៦,៦៦% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ១៤នាក់ ក្នុងនោះជនសង្ស័យជាអនីតិជន ០២នាក់ និងជនបរទេសសញ្ជាតិបង់ក្លាដេស ០១នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ១៤នាក់ មាន: អាយុក្រោម១៥ឆ្នាំ ១៣នាក់ និងអាយុពី១៨ឆ្នាំឡើង ០១នាក់ (ប្រគល់ឱ្យគ្រួសារ១៤នាក់) ក្នុងនោះចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ០២ករណី/០៨ករណី (ថយចុះ ០៦ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ អនីតិជន ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ០២នាក់ មាន: អាយុក្រោម១៥ឆ្នាំ ០១នាក់ និងអាយុ១៨ឆ្នាំឡើង ០១នាក់ (ប្រគល់ឱ្យគ្រួសារ ០២នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០១ | ០១ |
| -ការទិញពេស្យាចារកុមារ | ០១ | ០១ | ០១<br>(អ.នី ០១) |
| *សរុប* | *០២ ករណី* | *០២ នាក់* | *០២ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១២ករណី/០៧ករណី (កើនឡើង ០៥ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១២នាក់ ជនសង្ស័យជាអនីតិជន ០១នាក់ និងជនបរទេសសញ្ជាតិបង់ក្លាដេស ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១២នាក់ អាយុក្រោម១៥ឆ្នាំ ១២នាក់ (ប្រគល់ឱ្យគ្រួសារ ១២នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៩ | ០៩ | ០៩<br>(អ.នី០១) | បង់ក្លាដេស១ |
| -អំពើអាសអាភាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | ០៣ | |
| *សរុប* | *១២ ករណី* | *១២ នាក់* | *១២ នាក់* | *០១ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ១២.៧២៨នាក់(ស្ត្រី ៥.៣២៧នាក់) កុមារ ១.៥៤៥នាក់ (កុមារី ៧១៩នាក់)សកម្មភាពមានដូចជា៖

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងសមាហរណកម្មជនរងគ្រោះ បានទទួលចំនួន ២០នាក់ (ស្ត្រី ១៥នាក់)កុមារ ០២នាក់(កុមារី ០១នាក) មកពីប្រទេសចិន ១៤នាក់ ម៉ាឡេស៊ី ០៤នាក់ និងប្រទេសថៃ ០២នាក់ (ករណីអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ/បង្ខំ ១៤នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម ០២នាក់ ជួញដូរកម្លាំងពលកម្ម ០១នាក់ ជួញដូរផ្លូវភេទ ០១នាក់ និងងាយរងគ្រោះ ០២នាក់) បានសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ។
- មណ្ឌលសំចតប៉ោយប៉ែត បានទទួលពីប្រទេសថៃចំនួន ១២.៧០៨នាក់ (ស្ត្រី ៥.៣១២នាក់) កុមារ ១.៥៤៣នាក់ (កុមារី ៧១៨នាក់) បានបញ្ជូនទៅទទួលសេវាបន្តនៅអង្គការដៃគូ ដើម្បីផ្តល់សេវាជូនពលករមួយចំនួនដែលមិនមានលទ្ធភាពត្រឡប់ទៅស្រុកកំណើតវិញ។

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសន៍ជនរងគ្រោះ ដែលបានវិលត្រឡប់មកពីក្រៅប្រទេស ចំនួន ១៤នាក់(ស្រី) មកពីប្រទេសចិន ១២នាក់ អនីតិជន ០១នាក់ និងប្រទេសម៉ាឡេស៊ី ០២នាក់។ ជាលទ្ធផល រងគ្រោះដោយអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈទៅចិន ១២នាក់ និងរងគ្រោះដោយកេងប្រវ័ញ្ចប្រាក់ឈ្នួលនៅម៉ាឡេស៊ី ០២នាក់។
- **ខេត្តបន្ទាយមានជ័យ៖** ក្រុមការងារបានទទួល នឹងសម្ភាសន៍ជនទេសន្តប្រវេសន៍(ពលរដ្ឋខ្មែរ) ដែលអាជ្ញាធរថៃបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ចំនួន ១៣៥លើក មនុស្សចំនួន ១៣.៧២៧នាក់ (ស្ត្រី ៥.៧២៣នាក់) អនីតិជន ៩១៦នាក់។
- **ខេត្តឧត្តរមានជ័យ៖** បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ០៧ លើក មនុស្សចំនួន ៣៩នាក់ (ស្រី ២២នាក់) អនីតិជន ០១នាក់។
- **ខេត្តកោះកុង៖** បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន ៣៣លើក មនុស្សចំនួន ៥២៤នាក់(ស្រី ១៩៣នាក់ អនីតិជន ១០០នាក់)។
- **ខេត្តស្វាយរៀង៖** បានទទួលពលរដ្ឋខ្មែរដែលឆ្លងដែនខុសច្បាប់ ទៅធ្វើការនៅប្រទេសវៀតណាម ចំនួន ០១លើក មនុស្សចំនួន ០៣នាក់ (ស្រី)។
- **ខេត្តតាកែវ៖** បានទទួលពលរដ្ឋខ្មែរដែលវិលត្រឡប់ពីប្រទេសវៀតណាម ចំនួន ៩០នាក់ (ស្រី ០៩នាក់)។

### ឃ.២. ការផ្តល់សេវា និងការស្តារនីតិសម្បទាជនរងគ្រោះដោយអំពើជួញដូរមនុស្ស

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស

ដើម្បីទទួលសេវាស្នាក់នៅ និងការស្តារនីតិសម្បទា សរុបចំនួន ១០នាក់(ស្ត្រី)ជាករណីជួញដូរផ្លូវភេទ ដែលស្នាក់នៅទទួលសេវាពីអង្គការមូលនិធីA21។

**ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ទៅសហគមន៍វិញសរុបចំនួន ១៨នាក់ (ស្ត្រី ១៣នាក់) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទះ/បង្ខំ ១៣នាក់ ជួញដូរកម្លាំងពលកម្ម ០៥នាក់) ដោយបានការចូលរួមសហការគាំទ្រពីអង្គការដៃគូ។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានសហការជាមួយអង្គការវីនរ៉ក់ បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ចំនួន ០១លើក អ្នកចូលរួមចំនួន ៣០នាក់ (ស្រី ១២នាក់)នៅខេត្តបាត់ដំបង។
- **ខេត្តសៀមរាប** ក្រុមការងារយុវជន នៅក្នុងឃុំកែវពណ៌ ស្រុកពួក បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០១លើក អ្នកចូលរួមចំនួន ៣២នាក់ (ស្រី ១៩នាក់)។
- **ខេត្តព្រៃវែង** ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងការស៊ើបអង្កេតបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ តាមប្រព័ន្ធ Zoom ដល់ផែនប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងវរៈការពារព្រំដែន៦០៧ អ្នកចូលរួមចំនួន ០៦នាក់ (ស្រី ០២នាក់)។
- **ខេត្តតាកែវ** លេខាធិការដ្ឋាន គ.ខ.ប.ជ បានបើកវគ្គបណ្តុះបណ្តាលបំប៉នពង្រឹងសមត្ថភាពស្ត្រីថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ ចំនួន ០៣លើក អ្នកចូលរួមចំនួន ១៧០នាក់ (ស្រី១៦៣នាក់) ស្តីពីការពង្រឹង និងយន្តការទប់ស្កាត់ដល់ការជួញដូរមនុស្ស និងអំពើហឹង្សាក្នុងគ្រួសារ និងជួយទប់ស្កាត់ការធ្វើចំណាកស្រុកក្រៅប្រទេសខុសច្បាប់។
- **ខេត្តស្វាយរៀង** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន៥ បើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជ្រាបការយល់ដឹង អំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទ ស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារជាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារ សុខភាព និង សុវត្ថិភាព ការងារ និងការជួយសង្គ្រោះបឋម ចំនួន ០៦វគ្គ អ្នកចូលរួមចំនួន ១០៨នាក់ (ស្រី ៤៣នាក់) ។
- **ខេត្តបន្ទាយមានជ័យ** លេខាធិការដ្ឋាន គ.ខ.ប.ជ បើកវគ្គបំប៉នពង្រឹងសមត្ថភាព ស្ត្រីថ្នាក់ដឹកនាំ អ្នកចូលរួមចំនួន ១២០នាក់។
- **ខេត្តត្បូងឃ្មុំ** លេខាធិការដ្ឋាន គ.ខ.ប.ជ បានសហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី បើវគ្គបណ្តុះបណ្តាលបំពេញបន្ថែម ស្តីពី "ការគ្រប់គ្រង និងការបញ្ជូនករណីជនរងគ្រោះដោយអំពើ

ជួញដូរមនុស្សទៅកាន់សេវាគាំទ្រ” ជូនដល់សមាជិក សមាជិកា នៃក្រុមជំនាញទាំង ០៦ សមាជិក លេខាធិការដ្ឋានថ្នាក់ខេត្ត និងអង្គការសង្គមស៊ីវិល អ្នកចូលរួមចំនួន ២០នាក់។

- ខេត្តរតនគិរី មន្ទីរកិច្ចការនារីខេត្ត បានសហការជាមួយអង្គការឃែរ បើកវគ្គបណ្តុះបណ្តាល ស្តីអំពីកិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រី និងកុមារនៅកម្ពុជា អ្នកចូលរួមចំនួន ១៦នាក់ (ស្រី ១០នាក់)។

**ក.២. សិក្ខាសាលា**

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានរៀបចំសិក្ខាសាលាចំនួន ០២លើក៖
  - សិក្ខាសាលាបណ្តុះបណ្តាលលើ "គោលនយោបាយ និងបទដ្ឋានអប្បបរមា ពីកិច្ចការពារសិទ្ធិ ជនរងគ្រោះ និងគោលការណ៍ណែនាំ ស្តីពី បែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប" សិក្ខាកាមចូលរួមចំនួន ៨០នាក់ (ស្រី ២២នាក់) ដោយមានកិច្ចសហការគាំទ្រពីគម្រោងកម្មវិធី ASEAN-ACT នៅខេត្តបាត់ដំបង។
  - សិក្ខាសាលាពិគ្រោះយោបល់ចុងក្រោយ លើការធ្វើបច្ចុប្បន្នភាពសារាចរណែនាំ ០០៩ និងទម្រង់គ្រប់គ្រងជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស សិក្ខាកាមចូលរួមចំនួន ១១០នាក់ (ស្រី ៣៧នាក់) ដោយមានការគាំទ្រពីអង្គការរេដ:អន្តរជាតិ និងគម្រោងកម្មវិធី Asian ACT នៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង ។
- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសិក្ខាសាលា ចំនួន ០២លើក៖
  - សិក្ខាសាលាថ្នាក់ជាតិ ស្តីពីការរៀបចំផែនការជាតិ សម្រាប់អនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេស្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ ដែលរៀបចំដោយអង្គការ IOM សិក្ខាកាមចូលរួមចំនួន ៥៥នាក់ (ស្រី ១៦នាក់) នៅសណ្ឋាគារកាំបូឌីយ៉ាណា។
  - សិក្ខាសាលា កិច្ចប្រជុំពិនិត្យពិភាក្សា លើកទី២ និងធ្វើបច្ចុប្បន្នភាពសៀវភៅគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប សិក្ខាកាមចូលរួមចំនួន ៥២នាក់ (ស្រី ០៨នាក់) ដោយមានកិច្ចសហការគាំទ្រពីអង្គការ Asian ACT នៅសណ្ឋាគារស៊ាន់វេភ្នំពេញ។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

  លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖
  - ដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សា កែសម្រួលខ្លឹមសាររបាយការណ៍បូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្ត ឆ្នាំ២០២២ ចំនួន ០២លើក នៅសាលប្រជុំ គ.ជ.ប.ជ។
  - ដឹកនាំកិច្ចប្រជុំ ស្តីពីការធ្វើបទបង្ហាញពីសេវាកម្ម និងព័ត៌មាន នៃគំរោងមជ្ឈមណ្ឌល CASA ដែលស្នើឡើងដោយអង្គភាពការពារកុមារ CPU អ្នកចូលរួមចំនួន ១៧នាក់ (ស្រី ០៣នាក់) នៅសាលប្រជុំ គ.ជ.ប.ជ។
  - ដឹកនាំកិច្ចប្រជុំតាមប្រព័ន្ធវីដេអូអនឡាញ ស្តីពីការត្រៀមសម្រាប់កិច្ចប្រជុំទ្វេភាគី រវាង រដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលថៃ នៅសាលប្រជុំ គ.ជ.ប.ជ។

- បើកកិច្ចប្រជុំតាមប្រព័ន្ធវីដេអូអនឡាញ ស្តីពីយុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិត "រួមគ្នាលើកកម្ពស់ ការពារ និងគោរពសិទ្ធិកុមារ តាមរយៈការប្រើប្រាស់ប្រព័ន្ធអនឡាញប្រកបដោយការទទួលខុសត្រូវ" នៅសាលប្រជុំ គ.ជ.ប.ជ។

**ខ.២. ជំនួបពិភាក្សាការងារ**

- **ខេត្តសៀមរាប** លេខាធិការដ្ឋាន គ.ខ.ប.ជ បានទទួលប្រជុំពិភាក្សាការងារជាមួយអង្គការដៃគូជាតិ អន្តរជាតិ ចំនួន ០៦លើក ៖
  - បានទទួលជំនួបពិក្សាការងារអំពីគម្រោង និងខេត្តគោលដៅ របស់អង្គការ Winrock international ចំនួន ០១លើក នៅរដ្ឋបាលសាលាខេត្ត។
  - បានផ្តល់កិច្ចសម្ភាសន៍ជាមួយក្រុមអ្នកស្រាវជ្រាវវាយតម្លៃរបស់ IJM ស្តីពីកិច្ចសហការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរកម្លាំងពលកម្ម ចំនួន ០១លើក នៅរដ្ឋបាលសាលាខេត្ត។
  - បានជួបពិភាក្សាការងារជាមួយអង្គការមូលនិធិA21 ស្តីពីការអនុវត្តផែនការសកម្មភាពឆ្នាំ២០២២ លើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ០១លើក នៅរដ្ឋបាលសាលាខេត្ត។
  - បានទទួលជួបពិភាក្សាលើការអនុវត្តគម្រោងកិច្ចការពារជំនាន់ថ្មី ឬ Protection Plus ជាមួយអង្គការថ្លែនអន្តរជាតិ អង្គការសកម្មភាពដើម្បីកុមារ (APLE) អង្គការTPO អង្គការជំហានដំបូង និងអង្គការបណ្តាញសេវាទូរស័ព្ទកម្ពុជា ចំនួន ០១លើក តាមប្រព័ន្ធ Zoom។
  - បានទទួលជួបពិភាក្សាការងារជាមួយអង្គការជីវិតនៅកម្ពុជា អំពីការត្រៀមរៀបចំវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីវិធានការបង្វែរអនីតិជនជំទាស់នឹងច្បាប់ ចំនួន ០១លើក តាមប្រព័ន្ធ Zoom។
  - បានអនុញ្ញាតជូនប្រធានក្រុមការងារទេសន្តរប្រវេសន៍ ទទួលជួបជាមួយអ្នកវាយតម្លៃគម្រោង ស្តីពីលើកកម្ពស់សិទ្ធិការងាររបស់ពលករចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបនៅក្នុងប្រទេសថៃ ដែលអនុវត្តដោយអង្គការ We World ចំនួន ០១លើក នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។
- **ខេត្តបន្ទាយមានជ័យ** លេខាធិការដ្ឋាន គ.ខ.ប.ជ បានផ្តល់បទសម្ភាសជាមួយក្រុមការងាររបស់ក្រុមហ៊ុន RESEARCH និង Communication Group (RCG) សហការជាមួយអង្គការ IJM ដែលគោលបំណងនៃការជួបសម្ភាសមានពីរ៖
  - សិក្សាស្វែងយល់ពីបទពិសោធន៍នៃដំណើររឿងក្តី និងការងារប្រយុទ្ធប្រឆាំងលើបទល្មើសជួញដូរពលកម្មក្នុងស្រុក និងឆ្លងដែន។
  - ស្នើសុំមតិយោបល់ពីភាពខ្វះចន្លោះនៃការងារប្រយុទ្ធប្រឆាំងបទល្មើសខាងលើ និងអនុសាសន៍អំពីការធ្វើអោយប្រសើរឡើងនូវការងាររឿងក្តី ក៏ដូចជានីតិវិធីក្នុងកិច្ចសហការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរពលកម្មជាមួយស្ថាប័នពាក់ព័ន្ធនានា។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៦៧លើក មានអ្នកចូលរួមសរុប ៦០៤នាក់ (ស្រី ៤៩៩នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ២២លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ៤៥លើក។(ឧបសម្ព័ន្ធ១)

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន** គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួងស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

### គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

### ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមីនា ឆ្នាំ ២០២២

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ.....................ខែ..........ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ.........ឆ្នាំ២០២២

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ-ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៦៧លើក) មនុស្សចំនួន ៦០៤នាក់ (ស្រី ៤៩៩នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ<br>- ជាអធិបតីភាព ក្នុងពិធីបើកវគ្គបំប៉នសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជូនដល់ថ្នាក់ដឹកនាំរបស់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តបន្ទាយមានជ័យ។<br>- ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅវិមានសន្តិភាព។<br>- ជាអធិបតីភាព ក្នុងពិធីបើកវគ្គបំប៉នសមត្ថភាពស្ត្រីជាថ្នាក់ដឹកនាំ ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជូនដល់ថ្នាក់ដឹកនាំរបស់សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តប៉ៃលិន។<br>- ជាអធិបតីភាពបិទកម្មវិធី សិក្ខាសាលាកែសម្រួលសៀវភៅគោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប លើកទី២ នៅសណ្ឋាគារសាន់វេភ្នំពេញ។<br>- ចូលរួមក្នុងពិធីបើកសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ និងបូកសរុបលទ្ធផលប្រលងប្រណាំង ភូមិ-ឃុំ មានសុវត្ថិភាព របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសណ្ឋាគារសុខាភ្នំពេញ។<br>- ចូលរួមក្នុងវេទិកា ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្សតាមរយៈអនឡាញ ក្រោមប្រធានបទ កូវីដ-១៩ ការជួញដូរមនុស្ស និងបច្ចេកវិទ្យា ដែលរៀបចំដោយផ្នែកជួញដូរមនុស្សដោយ UNDOC អង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម នៅដឺហ្វេកធូរីភ្នំពេញ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ<br>- ជាអធិបតីភាពក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅខេត្តបាត់ដំបង។<br>- ចូលរួម និងទទួលស្ត្រីពពោះជំនួស នៅមន្ទីរពេទ្យ១៦ឧសភា។<br>- ចូលរួមពីធីប្រកាសគម្រោងនៅមជ្ឈមណ្ឌលទទួលពលករនៅស្រុកកំរៀង ខេត្តបាត់ដំបង។ |

- ចូលរួមកិច្ចប្រជុំក្រុមការងារយេនឌ័រ របស់ក្រសួងមហាផ្ទៃ នៅក្រសួងមហាផ្ទៃ។
- ជាអធិបតីភាពក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន រៀបចំដោយអង្គការ UNICEF។
- ចូលរួមក្នុងពិធីបើកសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២១ និងទិសដៅការងារឆ្នាំ២០២២ និងបូកសរុបលទ្ធផលប្រលងប្រណាំង ភូមិ-ឃុំ មានសុវត្ថិភាព របស់ក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសណ្ឋាគារសុខាភ្នំពេញ។
- ចូលរួមកិច្ចប្រជុំជាមួយអង្គការចាប់ដៃ នៅសាលប្រជុំ គ.ជ.ប.ជ។

▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**

- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ០៤ច្បាប់ លិខិតចូល ០៦ច្បាប់។
- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ០១ច្បាប់ លិខិតចូល ១២ច្បាប់។
- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រៀងរាល់កិច្ចប្រជុំ។
- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកុម្ភៈ ឆ្នាំ២០២២ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- បូកសរុបរបាយការណ៍ប្រចាំខែកុម្ភៈ ឆ្នាំ២០២២ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាគារវីគី។
- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។
- គ្រប់គ្រងទំព័រហ្វេសប៊ុក របស់លោកជំទាវអគ្គលេខាធិការ គជ.ប.ជ.។
- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ wiki ncct convert ជាPDF បានចំនួន៩៦ច្បាប់ និងបានចងក្រងជាសៀវភៅដាក់ជូន លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និងជូនលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- អាប់ឡូតរូបភាពសកម្មភាព គ.ជ.ប.ជ និង គ.ខ.ប.ជ ចូលបណ្ណាល័យរូបភាពក្នុងប្រព័ន្ធ Wiki បានចំនួន០៨សកម្មភាព។

▪ **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចូលរួមក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ ជ.ប.ជ.នៅខេត្តបាត់ដំបង។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- ឯកឧត្តម ឧត្តមសេនីយ៍ឯក អគ្គលេខាធិការរង គ.ជ.ប.ជ
  - បានចូលរួមសិក្ខាសាលាថ្នាក់តំបន់ ដោយមានការធ្វើបទបង្ហាញ និងចែករំលែកបទពិសោធន៍ ពី៤ប្រទេសរួមមាន ព្រះរាជណាចក្រកម្ពុជា ព្រះរាជណាចក្រថៃឡង់ដ៍ ឥណ្ឌូនេស៊ី និងភូមា ប្រធានបទ )ការបណ្តុះបណ្តាលថ្នាក់តំបន់ ស្តីពី សេចក្តីផ្តើម នៃទស្សនទាន ការធ្វើសមាហរណកម្ម ប្រកបដោយនិរន្តរភាព សម្រាប់រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល រៀបចំ និងឧបត្ថម្ភ សម្របសម្រួលដោយ អង្គការ IOM ប្រចាំកម្ពុជា នៅសណ្ឋាគារសោម៉ាទេវី ខេត្តសៀមរាប។
  - បានចូលរួមធ្វើគ្រូឧទ្ទេសវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសណ្ឋាគារខេមរា ខេត្តបាតដំបង។
- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះ អមដំណើរលោកជំទាវអគ្គលេខាធិការ គ.ជ.ប.ជ ទៅមន្ទីពេទ្យ១៦ឧសភា ដើម្បីធ្វើការសម្របសម្រួលស្ត្រីកេស៊ីពពោះជំនួស០២រូប ដែលភាគីវៀតណាម បានបង្ក្រាប និងនាំខ្លួនឱ្យមន្ត្រីមានសមត្ថកិច្ចកម្ពុជា។

▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**

- លោកឧត្តមសេនីយ៍ទោ ប្រធានក្រុមជំនួយកិច្ចការការយុត្តិធម៌ បានចូលរួមធ្វើជាគ្រូបង្គោល ចុះទៅបណ្តុះបណ្តាលដល់ថ្នាក់ដឹកនាំ និងមន្ត្រីជួរមុខក្នុងស្រុកចំនួន ១២ មកពីលេខាធិការដ្ឋាន គ.ខ.ប.ជ ចំនួន០៥ ខេត្ត (ប៉ៃលិន បាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ និងខេត្តពោធិ៍សាត់ ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន នៅសាលប្រជុំផ្នែកបណ្តុះបណ្តាលបន្តនៃមន្ទីរសុខាភិបាលខេត្តបាត់ដំបង សហការរៀបចំដោយក្រសួងសុខាភិបាល និងអង្គការមូលនីធិអប់រំកុមារ អង្គការសហប្រជាតិ UNICEF។

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

- លោកជំទាវ ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង គ.ជ.ប.ជ បានសហការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន កិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាមួយក្រសួងសុខាភិបាល ដោយមានជំនួយឧបត្ថម្ភពីសហភាពអឺរ៉ុប នៅសាលប្រជុំផ្នែកបណ្តុះបណ្តាលបន្តមន្ទីសុខាភិបាល ខេត្តបាត់ដំបង។

| | |
|---|---|
| | - លោកជំទាវ ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប សិក្ខាសាលានេះធ្វើឡើងក្រោមកិច្ចសហការរវាង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និងប្រធានគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជានៃអង្គការវិនរ៉ុក នៅសាលាខេត្តបាត់ដំបង។<br>- លោកជំទាវ ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង នៅសាលប្រជុំផ្នែកបណ្តុះបណ្តាលបន្តមន្ទីរសុខាភិបាល ខេត្តបាត់ដំបង បានបន្តធ្វើវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភ។<br>▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម អគ្គលេខាធិការរង គ.ជ.ប.ជ បានអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីការបង្កើតប្រព័ន្ធទំនាក់ទំនង សម្រាប់មន្ត្រីបង្គោលតំណាងថ្នាក់ជាតិ ACTIP តាមប្រព័ន្ធអនឡាញ ដែលមានរយៈពេលពីរថ្ងៃ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៤៥លើក អ្នកចូលរួមសរុបចំនួន ៦០៤នាក់ (ស្រី ៤៩៩នាក់)** | |
| ខេត្តកណ្តាល | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំត្រីមាសទី១ ឆ្នាំ២០២២ និងលើកទិសដៅអនុវត្តបន្ត អ្នកចូលរួមចំនួន២៥នាក់ ស្រី១៨នាក់។<br>- ក្រុមការងារខេត្ត ដឹកនាំដោយលោកជំទាវ អភិបាលរង នៃគណៈអភិបាលខេត្ត បានចូលរួមពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នូវសៀវភៅរបាយការណ៍ របស់គណៈកម្មាធិការអាស៊ាន ស្តីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ ស្តីពីអត្តសញ្ញាណស្របច្បាប់សម្រាប់ស្ត្រី និងកុមារក្នុងតំបន់អាស៊ាន តាមប្រព័ន្ធ Zoom ក្រោមអធិបតីភាពឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។<br>- បានចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិ ដើម្បីផ្តល់ធាតុចូលលើសេចក្តីព្រាងច្បាប់ ស្តីពីកិច្ចការពារកុមារនៃព្រះរាជាណាចក្រកម្ពុជា។<br>- បានចូលរួមប្រជុំ ស្តីពីការត្រួតពិនិត្យការងារប្រឆាំងការសម្អាតប្រាក់ និងពង្រឹងកិច្ចសហការស៊ើបអង្កេតស្រាវជ្រាវផលនៃបទល្មើសសម្អាតប្រាក់ ដែលបានមកពីបទល្មើសជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ និងទម្រង់ផ្សេងទៀតតាមប្រព័ន្ធ Zoom។<br>- បានចូលរួមក្នុងវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ ការកេងប្រវ័ញ្ចផ្លូវភេទកុមារ នៅសណ្ឋាគារភ្នំពេញ។<br>- ក្រុមការងារក្រុង-ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែកុម្ភៈ ចំនួន០៥លើក អ្នកចូលរួមចំនួន១៣០នាក់ ស្រី៦៧នាក់។<br>- មន្ត្រីការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តចំនួន០៥នាក់ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់សញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស តាមប្រព័ន្ធ Zoom អ្នកចូលរួមចំនួន១៤០នាក់ ស្រី៥៥នាក់។ |

| | |
|---|---|
| ខេត្តក្រចេះ | - ស្នងការដ្ឋាននគរបាលខេត្ត បានចាត់មន្ត្រីនគរបាលចំនួន០៦រូប ចូលរួមវគ្គបណ្តុះបណ្តាលថ្នាក់ជាតិ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស រៀបចំដោយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន សហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ។ |
| ខេត្តព្រៃវែង | - លោកជំទាវ អភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមជាអធិបតីភាពបើកវគ្គណែនាំ ស្តីពីការអនុវត្តគម្រោងកិច្ចការពារកុមារ និងការគ្រប់គ្រងថវិកាជូនដល់ក្រុមការងារកិច្ចការពារកុមារ និងមន្ត្រីពិនិត្យបញ្ជាក់នៃគម្រោងលើកកម្ពស់សេវាសង្គម ដែលទទួលការគាំទ្ររបស់យូនីសេហ្វដល់ក្រុមការងារកិច្ចការពារកុមារ និងមន្ត្រីទទួលបន្ទុកខេត្តព្រៃវែង ក្រចេះ និងខេត្តរតនគិរី រៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងមហាផ្ទៃ និងគាំទ្រដោយអង្គការយូនីសេហ្វ។<br>- ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំគណៈបញ្ជាការឯកភាពខេត្ត ណែនាំដល់ក្រុង ស្រុក និងអ្នកពាក់ព័ន្ធ ឱ្យធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋ អំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងករណីពពោះជំនួស ដើម្បីជៀសផុតអំពីការជួញដូរមនុស្ស តាមប្រព័ន្ធ Zoom។ |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានដឹកនាំកិច្ចប្រជុំត្រួតពិនិត្យការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២២ អ្នកចូលរួមចំនួន៧៦នាក់ ស្រី៣៦នាក់ តាមប្រព័ន្ធ Zoom។<br>- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំកិច្ចប្រជុំប្រចាំខែកុម្ភៈ ឆ្នាំ២០២២ ចំនួន០៥លើក អ្នកចូលរួមចំនួន១៦១នាក់ ស្រី៥៥នាក់៖<br>○ ក្រុមការងារស្រុកសូទ្រនិគម ចំនួន០១លើក អ្នកចូលរួមចំនួន៣២នាក់ ស្រី០៩នាក់។<br>○ ក្រុមការងារស្រុកពួក ចំនួន ០១លើក អ្នកចូលរួមចំនួន៤៤នាក់ ស្រី១៦នាក់។<br>○ ក្រុមការងារស្រុកស្វាយលើ ចំនួន ០១លើក អ្នកចូលរួមចំនួន២២នាក់ ស្រី០៨នាក់។<br>○ ក្រុមការងារស្រុកអង្គរជុំ ចំនួន០២លើក អ្នកចូលរួមចំនួន៦៣នាក់ ស្រី២២នាក់។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំ និងវគ្គបណ្តុះបណ្តាលពាក់ព័ន្ធចំនួន០៥លើក៖<br>○ លោកជំទាវប្រធានលេខាធិការដ្ឋាន បានចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងលទ្ធផលការងារនៃការអនុវត្តផែនការសកម្មភាពឆ្នាំ២០២១ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២២ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ចំនួន០១លើក នៅរដ្ឋបាលសាលាខេត្ត។<br>○ លោកជំទាវប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំ របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្តលើទី៣២ អាណត្តិទី៣ ចំនួន ០១លើក តាមប្រព័ន្ធ Zoom។<br>○ ឯកឧត្តមអភិបាល នៃគណៈភិបាលខេត្ត និងជាប្រធាន គ.ខ.ប.ជ និងលោកជំទាវប្រធានលេខាធិការដ្ឋាន បានអញ្ជើញចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២-២០២១ និងលើកផែនការការងារឆ្នាំ២០២២ របស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចំនួន០១លើក តាមប្រព័ន្ធ Zoom។ |

| | |
|---|---|
| | ○ លោកជំទាវប្រធានលេខាធិការដ្ឋាន បានចូលរួមកិច្ចប្រជុំជាមួយអង្គការ UNICEF ស្ដីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០២២ របស់ក្រុមការងារកិច្ចការពារកុមារ ចំនួន០១លើក តាមប្រព័ន្ធ Zoom។<br>- លោកជំទាវប្រធានលេខាធិការដ្ឋាន បានចូលរួមពិធីផ្សព្វផ្សាយដាក់ឱ្យប្រើប្រាស់នូវសៀវភៅរបាយការណ៍របស់គណៈកម្មាធិការអាស៊ាន ស្ដីពីការលើកកម្ពស់ និងការពារសិទ្ធិស្ត្រី និងកុមារ (ACWC) ស្ដីពីអត្តសញ្ញាណស្របច្បាប់សម្រាប់ស្ត្រីនិងកុមារ ក្នុងតំបន់អាស៊ាន តាមប្រព័ន្ធ Zoom។ |
| **ខេត្តឧត្តរមានជ័យ** | - បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារ អ្នកចូលរួមចំនួន១៥នាក់ ស្រី១០នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្ដីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន។ |
| **ខេត្តស្វាយរៀង** | - គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំ ស្ដីពីវឌ្ឍនភាពការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆ្នាំ២០២១ និងទិសដៅបន្តឆ្នាំ២០២២ អ្នកចូលរួមចំនួន៥៧នាក់ ស្រី២៧នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស តាមប្រព័ន្ធ Zoom។ |
| **ខេត្តបន្ទាយមានជ័យ** | - ប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ លើសេចក្ដីព្រាងបទដ្ឋាននីតិវិធីប្រតិបត្តិការ ស្ដីពីកិច្ចការពារកុមារ។<br>- ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមប្រជុំត្រៀមបើកវគ្គបណ្តុះបណ្តាល ស្ដីពី«កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន» តាមប្រព័ន្ធ Zoom។<br>- ប្រធានលេខាធិការដ្ឋាន និងក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ បានចូលរួមរៀនវគ្គបណ្តុះបណ្តាល ស្ដីពី«កិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន» នៅសាលាខេត្តបាត់ដំបង។<br>- ស្នងការដ្ឋាននគរបាលខេត្ត<br>○ បានចូលរួមវគ្គបណ្តុះបណ្តាល ស្ដីពីកិច្ចការពារកុមារ ពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ តាមប្រព័ន្ធ Zoom នៅរាជធានីភ្នំពេញ។<br>○ បានចូលរួមវគ្គបណ្តុះបណ្តាលលើកទី២ ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងនីតិវិធីស៊ើមអង្កេត តាមប្រព័ន្ធ Zoom។<br>○ បានចូលរួមវគ្គបណ្តុះបណ្តាល ស្ដីពីកិច្ចការពារកុមារ និងកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងរំលោភបំពាន ធ្វើនៅមន្ទីរសុខាភិបាលខេត្តបាត់ដំបង។ |
| **ខេត្តមណ្ឌលគិរី** | - បានចូលរួមវគ្គបណ្តុះបណ្តាលលើកទី២ ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងនីតិវិធីស៊ើមអង្កេត តាមប្រព័ន្ធ Zoom។ |
| **ខេត្តកំពង់ឆ្នាំង** | - លេខាធិការដ្ឋាន គជ.ប.ខ. ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែ កុម្ភៈ ឆ្នាំ២០២២ តាមប្រព័ន្ធ Zoom។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធ Zoom ស្ដីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ និងនីតិវិធីស៊ើបអង្កេតករណីជួញដូរមនុស្ស អំឡុងពេលកូវីដ-១៩។ |

| | |
|---|---|
| ខេត្តប៉ៃលិន | - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការយល់ដឹងពីមូលដ្ឋាន នៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកិច្ចការពារកុមារដល់បុគ្គលិកសង្គម និងមន្ត្រីជួរមុខនៅសហគមន៍ ក្រោមអធិបតីភាព លោក ឡៅ វេង អគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តាមប្រព័ន្ធ Zoom។<br>- បានចូលរួមកិច្ចប្រជុំ ពិភាក្សាត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន ក្រោមអធិបតីភាព លោកជំទាវ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ តាមប្រព័ន្ធ Zoom។<br>- លោកជំទាវ បាន ស្រីមុំ អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការកិត្តិយសសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងជាអនុប្រធានគណៈកម្មាធិការកិត្តិយសសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព បានចូលរួមវគ្គបំប៉នពង្រឹងសមត្ថភាពស្ត្រីថ្នាក់ដឹកនាំ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាសមាជិកគណៈកម្មាធិការកណ្តាល អនុប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ និងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងការរំលោភបំពាន ដើម្បីសមត្ថភាពបន្ថែម ដល់មន្ត្រីជំនាញ ក្រោមអធិបតីភាព លោកជំទាវ ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលាខេត្តបាត់ដំបង។ |
| ខេត្តកំពង់ធំ | - បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារ តាមប្រព័ន្ធ Zoom នៅសណ្ឋាគារសាន់វ៉េ រាជធានីភ្នំពេញ។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធ Zoom។ |